**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ....១១១.៣៨៣../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២៣.. ខែ.កុម្ភៈ.. ឆ្នាំ២០.១២

**គោរពជូន**

**-ឯកឧត្តមអភិបាលនៃគណៈអភិបាល ខេត្តកំពង់ចាម**
**-ឯកឧត្តមអភិបាលនៃគណៈអភិបាល ខេត្តក្រចេះ**
**-ឯកឧត្តមអភិបាលនៃគណៈអភិបាល ខេត្តកំពង់ធំ**

**កម្មវត្ថុ:** ផែនការសកម្មភាពនិងថវិកាឆ្នាំ២០១២ និងឆ្នាំ២០១៣ (រយៈពេល១៨ខែ) នៃគម្រោងបែងចែកដីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED)។

**យោង:** -កិច្ចព្រមព្រៀងហិរញ្ញប្បទានចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ រវាង ព្រះរាជាណាចក្រកម្ពុជា និងសមាគមអភិវឌ្ឍអន្តរជាតិ។

-សារទូរលេខអេឡិចត្រូនិចរបស់ធនាគារពិភពលោកចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការមិនជំទាស់លើផែនការសកម្មភាព និងថវិកាឆ្នាំ២០១២ និង ឆ្នាំ ២០១៣ (រយៈពេល១៨ខែ) សម្រាប់គម្រោងបែងចែកដីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED)។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត ជ្រាបថា: ធនាគារពិភពលោកកាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១២ បានផ្តល់ភាពមិនជំទាស់លើផែនការសកម្មភាពនិងថវិកាឆ្នាំ២០១២ និង ២០១៣ (រយៈពេល១៨ខែ) សម្រាប់អនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច LASED រហូតដល់ត្រឹមថ្ងៃបញ្ចប់គម្រោង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣ ដែលក្នុងនោះ:

| | |
|---|---|
| • គម្រោងLASEDថ្នាក់ជាតិ (LASED/GSSLC/MLMUP) | $ 264,977.20 |
| • គម្រោងLASEDថ្នាក់ជាតិ (LASED/NCDD/MoI) | $6,204,177.89 |
| • គម្រោងLASEDខេត្តកំពង់ចាម | $206,921.70 |
| • គម្រោងLASEDខេត្តក្រចេះ | $756,242.40 |
| • គម្រោងLASEDខេត្តកំពង់ធំ | $352,753.06 |
| **សរុបថវិកាធនាគារពិភពលោក** | **$7,785,072.25** |

ផ្អែកលើសេចក្តីជូនដំណឹងនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំសេចក្តីសម្រេចរួមតាមខេត្តគោលដៅនីមួយៗ រួចផ្ញើមកលេខាធិការដ្ឋានគ.ជ.អ.ប ដើម្បីផ្តល់នីត្យានុកូលភាព។ ទន្ទឹមនឹងគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំកិច្ចព្រមព្រៀងជាមួយមន្ទីរវិស័យ អង្គភាពស្រុក និងឃុំ ដែលបានឯកភាពគ្នាស្នើឡើង ដូចមាននៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១២ និងឆ្នាំ២០១៣។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត មេត្តាជ្រាប និងជួយសហការឲ្យមានប្រសិទ្ធិភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

**ជ.ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ចម្លងជូន**

-លេខាធិការដ្ឋានគ.ជ.អ.ប

-អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ

-អគ្គលេខាធិការដ្ឋានជីសម្បទានសង្គមកិច្ច

-ឯកសារកាលប្បវត្ត

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| យោបល់ថ្នាក់ដឹកនាំ | |
|---|---|
| ឯកភាព<br>ជាន់ ចំរើន | **សូមគោរពជូន**<br>**ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**<br>**តាមរយៈ** ឯកឧត្តមអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប<br>**កម្មវត្ថុៈ** សំណើសុំចុះហត្ថលេខា លើសេចក្ដីជូនដំណឹងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៃខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តកំពង់ធំ ស្ដីអំពីផែនការសកម្មភាពនិងថវិកា សម្រាប់អនុវត្តគម្រោង LASED ប្រចាំឆ្នាំ២០១២ និងឆ្នាំ២០១៣ (រយៈពេល១៨ខែ) ។<br>**យោងៈ** អ៊ីម៉ែលរបស់ធនាគារពិភពលោក ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១២ ស្ដីពីការមិនជំទាស់លើផែនការសកម្មភាពនិងថវិកា ឆ្នាំ២០១២និង ឆ្នាំ ២០១៣ (រយៈពេល១៨ខែ) របស់គម្រោង LASED ។<br>សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុនិងយោងខាងលើខ្ញុំសូមគោរពជម្រាបជូនឯកឧត្តមមេត្តាជ្រាបថាៈ ធនាគារពិភពលោក កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ បានផ្ដល់ការមិនជំទាស់លើផែនការសកម្មភាព និងថវិកា (រយៈពេល១៨ខែ) របស់គម្រោង LASED លើថវិកាសរុបចំនួន ៧,៧៨៥,០៧២.២៩ដុល្លា សម្រាប់អនុវត្តក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣ រហូតដល់ត្រឹមថ្ងៃបញ្ចប់គម្រោង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣ ក្នុងនោះ:<br>-គម្រោងLASED ថ្នាក់ជាតិ (LASED/GSSLC/MLMUP) ២៦៤,៩៧៧.២០ ដុល្លា<br>-គម្រោងLASED ថ្នាក់ជាតិ (LASED/NCDD/MoI) ៦,២០៤,១៧៧.៨៩ ដុល្លា<br>-គម្រោងLASED ខេត្តកំពង់ចាម ២០៦,៩២១.៧០ ដុល្លា<br>-គម្រោងLASED ខេត្តក្រចេះ ៧៥៦,២៤២.៤០ ដុល្លា<br>-គម្រោងLASED ខេត្តកំពង់ធំ ៣៥២,៧៥៣.០៦ ដុល្លា<br>អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមឯកឧត្តមមេត្តាពិនិត្យ សម្រេច និងចុះហត្ថលេខាលើសេចក្ដីជូនដំណឹងនេះដោយអនុគ្រោះ។<br>សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។ |

ភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១២

**ប.ក, ប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី**

ហ៊ុន. ម៉ាសុណាក